ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបំបែកសង្កាត់បឹងទំពន់ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំបែកសង្កាត់បឹងទំពន់ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ ជា០២ គឺ **សង្កាត់បឹងទំពន់ទី១** និង**សង្កាត់បឹងទំពន់ទី២** ដូចខាងក្រោមៈ

www.pheakdeylaw.com

- សង្កាត់បឹងទំពន់ទី១ មានភូមិចំនួន១១ គឺ ភូមិចំរើនផល ភូមិចំរើនផល១ ភូមិចំរើនផល២ ភូមិចំរើនផល៣ ភូមិចំរើនផល៤ ភូមិសន្សំកុសល១ ភូមិសន្សំកុសល២ ភូមិសន្សំកុសល៣ ភូមិសន្សំកុសល៤ ភូមិសន្សំកុសល៥ និងភូមិសន្សំកុសល៦
- សង្កាត់បឹងទំពន់ទី២ មានភូមិចំនួន១១ គឺ ភូមិក្បាលទំនប់ ភូមិក្បាលទំនប់១ ភូមិក្បាលទំនប់២ ភូមិក្បាលទំនប់៣ ភូមិត្នោតជ្រុំ ភូមិត្នោតជ្រុំ១ ភូមិត្នោតជ្រុំ២ ភូមិត្នោតជ្រុំ៣ ភូមិត្នោតជ្រុំ៤ ភូមិត្នោតជ្រុំ៥ និងភូមិត្នោតជ្រុំ៦។

ព្រំប្រទល់រដ្ឋបាលសង្កាត់បឹងទំពន់ទី១ និងសង្កាត់បឹងទំពន់ទី២ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២.-

ត្រូវបានផ្ទេរទីតាំងសាលាសង្កាត់បឹងទំពន់ដែលស្ថិតនៅក្នុងភូមិសន្សំកុសល២ ទៅជាសាលាសង្កាត់បឹងទំពន់ទី១។

ទីតាំងសាលាសង្កាត់បឹងទំពន់ទី២ ត្រូវស្ថិតនៅក្នុងភូមិត្នោតជ្រុំ១។

មាត្រា៣.-

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសង្កាត់បឹងទំពន់ទី១ និងសង្កាត់បឹងទំពន់ទី២ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា៤.-

ការបំបែកសង្កាត់បឹងទំពន់ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ស្របតាមខ្លឹមសារមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាសង្កាត់បឹងទំពន់ត្រូវបន្តគ្រប់គ្រងរដ្ឋបាលសង្កាត់បឹងទំពន់ រហូតដល់មានក្រុមប្រឹក្សាសង្កាត់បឹងទំពន់ទី១ និងក្រុមប្រឹក្សាសង្កាត់បឹងទំពន់ទី២ មកជំនួស។

មាត្រា៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌមានជ័យ គណៈអភិបាលខណ្ឌមានជ័យ ក្រុមប្រឹក្សាសង្កាត់បឹងទំពន់ ក្រុមប្រឹក្សាសង្កាត់បឹងទំពន់ទី១ និងក្រុមប្រឹក្សាសង្កាត់បឹងទំពន់ទី២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com

ក្រសួងមហាផ្ទៃ
រដ្ឋបាលរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

ផែនទីព្រំប្រទល់រដ្ឋបាលសង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលត្រូវបំបែកជា ២ គឺ : សង្កាត់បឹងទំពន់ទី១ និងសង្កាត់បឹងទំពន់ទី២

(ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦)



N

មាត្រដ្ឋាន ១/៧,០០០

កំណត់សម្គាល់ :

Projection UTM Zone 48N
Tatum WGS-1984
Unit Meter

-ព្រំប្រទល់ភូមិ
-ព្រំប្រទល់សង្កាត់
-ព្រំប្រទល់ខណ្ឌ